# គោរពជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

# នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា

*កម្មវត្ថុៈ ការផ្សាយពីស្នាដៃសម្តេចក្នុងទស្សនាវដ្តី «កិច្ចការបរទេស» ។*

ដូចបានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រីក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសសូមជំរាបជូនសម្តេចថាទស្សនាវដ្តី "កិច្ចការបរទេស" (Foreign Affairs Review) ដែលជាទស្សនាវដ្តីអ្នកនយោបាយ និង អ្នកការទូតអាមេរិច និង បរទេសភាគច្រើននិយមអាននោះ បានចុះផ្សាយអត្ថបទមួយសរសេរដោយលោក ពីតឺ ស៊ូធែឡាន (Peter D. Sutherland) ជាអតីតអគ្គនាយកអង្គការ GATT ពីឆ្នាំ ១៩៩៣ ដល់ ១៩៩៥ និង ជានាយកស្ថានិកអង្គការ WTO ហើយបច្ចុប្បន្នជានាយកក្រុមហ៊ុន BP p.l.c and Goldman Sachs International ហើយដែលមួយភាគលើកឡើងពីជោគជ័យរបស់សម្តេចក្នុងការដឹកនាំប្រទេសឆ្ពោះទៅកាន់កិច្ចអភិវឌ្ឍន៍ និង បន្សីប្រទេសទៅក្នុងយន្តការសេដ្ឋកិច្ចអន្តរជាតិ ។

នៅក្នុងអត្ថបទរបស់លោកដែលមានចំនងជើងថា «បណ្តាប្រជាជាតិដែលកំពុងប្រែប្រួល» (Transforming Nations) លោក ពីតឺ បាននិយាយពីផលប៉ះពាល់ជាវិជ្ជមានទាក់ទិនទៅនឹងការចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មអន្តរជាតិ ពិសេសអាស្រ័យតាមនីតិវិធីនៃការសូមចូលជាសមាជិកនេះតែម្តង ។ នៅពេលដែលអ្នកផងត្រឹមតែគិតបែបសាមញ្ញថា ចូលជាសមាជិក WTO គឺដើម្បីក្លាយខ្លួនមានបាននោះ គេត្រូវតែដណ្តឹងសួរខ្លួនឯងថាបើយ៉ាងនេះមែន ហេតុអីបានជាប្រទេសអ្នកមានដូចជាចិន និង អារ៉ាប៊ី សេអ៊ូឌីត ទ្រាំវេទនាចរចារាប់ឆ្នាំដើម្បីចូលអង្គការនេះធ្វើអ្វី បើនេះជាប្រទេសអ្នកមានស្រាប់ទៅហើយនោះ ( ប្រទេសចិនដាក់ពាក្យចូលជាមួយអង្គការ GATT នៅឆ្នាំ ១៩៨៦ ហើយត្រូវបានអង្គការ WTO ទទួលជាសមាជិកនៅឆ្នាំ ២០០១ ហើយប្រទេសអារ៉ាប៊ី សេអ៊ូឌីត ត្រូវចរចាអស់រយៈពេល ១២ ឆ្នាំទើបបានចូលជាសមាជិក) ?

តាមលោក ពីតឺ ការទ្រាំលំបាកវេទនាចរចាដើម្បីចូលជាសមាជិក WTO នេះគឺអាស្រ័យការមើលឃើញរបស់មេដឹកនាំដែលយល់ឃើញពីភាពចាំបាច់ដែលត្រូវមានការផ្លាស់ប្តូរ ហើយបានប្តេជ្ញាជំនះភាពអភិរក្ស ទំលាប់ចាស់ និង ផលប្រយោជន៍បក្ខពួក ដើម្បីធ្វើកំនែទំរង់ ។ ឥស្សរជនបីរូបដែលបានឈានមុខក្នុងកិច្ចការនេះ គឺសម្តេចនាយករដ្ឋមន្ត្រី ហ៊ុនសែន លោក តេង ស៊ាវពីញ និង ព្រះមហាក្សត្រ អាប់ឌុឡា នៃប្រទេសអារ៉ាប៊ី សេអ៊ូឌីត។

លោក ពីតឺ ក៏បានទទួលស្គាល់ផងដែរថា ស្នាដៃទាំងនេះ មិនមែនជាស្នាដៃតែឥស្សរជនទាំងបីអង្គឯងនោះទេ តែទាំងលោក ហ៊ុនសែន ទាំងលោក តេង ស៊ាវពីញ ទាំងព្រះមហាក្សត្រ អាប់ឌុឡា ត្រូវបានជួយដោយមន្ត្រីដ៏មានជំនាញៗដែលបានទៅធ្វើការចរចានៅ សឺនែវ និង អ្វីដែលសំខាន់ទៀតនោះ គឺការប្រឹងប្រែងរបស់មន្ត្រីនានានៅថ្នាក់ជាតិ និង ថ្នាក់ខេត្តក្នុងប្រទេសនីមួយៗនោះឯង ។ ប៉ុន្តែអ្វីដែលកំនត់ គឺការដឹកនាំប្រកបដោយការប្តេជ្ញាចិត្ត និង ឥទ្ធិពលរបស់អ្នកដឹកនាំប្រទេសដែលបានដើរតួ ។ ក្រៅពីបានលើកត្រួសៗនូវជីវប្រវត្តិរបស់សម្តេច (ទំព័រ ១២៨) លោក ពីតឺ ក៏បានរៀបរាប់ពីកិច្ចអភិវឌ្ឍន៍ដ៏គួរអោយកត់សំគាល់របស់កម្ពុជាចំនួនពីរទំព័រ (ទំព័រ ១២៨ ដល់ ១៣០) ដែលខ្ញុំបាទសូមបកទាំងស្រុងជូនសម្តេចដូចខាងក្រោមៈ

ទោះបីជាពួកខ្មែរក្រហមនៅតែបន្តសកម្មភាពយោធានៅតាមព្រំដែនថៃយ៉ាងណាក្តី ក៏ចាប់ពីដើមទស្សវត្ស ៩០ មក ប្រទេសកម្ពុជាបានទុកសោកនាដកម្មប្រល័យពូជសាសន៍នៅពីក្រោយហើយបានចាប់ផ្តើមដំណើរការកែទំរង់សេដ្ឋកិច្ច ។ ក្នុងរយៈពេលតែប៉ុន្មានឆ្នាំ បទពិសោធន៍ដ៏គួរអោយកត់សំគាល់ក្នុងកិច្ចសន្ទនារវាងវិស័យរដ្ឋ នឹងឯកជន បានចាប់ផ្តើមក្រោមការដឹកនាំផ្ទាល់របស់លោក ហ៊ុនសែន ។ កិច្ចពិភាក្សានេះនៅតែបន្តប្រកបដោយភាពក្លៀវក្លារហូតដល់បច្ចុប្បន្ននេះ ។ ក្រោមមគ្គុទ្ទេសន៍របស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិនៃធនាគារពិភពលោក កិច្ចសន្ទនានេះបានធានាអោយផ្នែកឯកជនមានលទ្ធភាពចូលរួមក្នុងការតាក់តែងគោលនយោបាយ ដែលជាការអភិ-វឌ្ឍន៍មួយធានាដល់អនាគតរបស់ប្រជាជាតិហើយដែលបើសិនគ្មានចំនុចនេះទេ គេមិនអាចគិតទៅដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រទេសជាតិក្នុងទិសដៅយូរអង្វែងបានទេ ។

ពាក្យសុំចូលជាសមាជិក WTO របស់កម្ពុជាដែលបានដាក់ក្នុងឆ្នាំ ១៩៩៤ ត្រូវបានទុកចោលនៅទីក្រុង សឺនែវ អស់រយៈពេលប្រាំឆ្នាំ ។ ក្នុងរយៈពេលនោះ ពួកកម្ពុជាបានត្រៀមរៀបចំដើម្បីយថាហេតុនៃការចរចានានាដើម្បីចូលជាសមាជិក ។ រដ្ឋាភិបាលលោក ហ៊ុនសែន បានសំរួលរចនាសំព័ន្ធពន្ធនាំចូលរបស់កម្ពុជាអោយនៅត្រឹមបួនអត្រា និង បានបន្ថយពន្ធជាទូទៅអោយថយពីអតិបរមា ៣៥ ភាគរយមកនៅក្រោម ២០ ភាគរយវិញ ។ នៅពេលដែលការចរចាដំណើរការហើយនោះ ប្រទេសកម្ពុជាបានប្រកាន់យកនូវវិធានការនានាប្រកបដោយទស្សនៈវែងឆ្ងាយនិងយ៉ាងស៊ីជំរៅនៅក្នុងវិស័យសេវាដើម្បីធានាអោយមានសេវាមួយប្រកបដោយប្រសិទ្ធភាពនិងមានភាពប្រកួតប្រជែងដើម្បីគាំទ្រដល់កិច្ចអភិវឌ្ឍន៍ឧស្សាហកម្ម និង កសិកម្ម ។